GC LiFE



# ធានារ៉ាប់រងបន្ថែមសម្រាប់ជំងឺធ្ងន់ធ្ងរ

ការការពារជំងឺធ្ងន់ធ្ងរ ៣៩ប្រភេទ ជួយសង្គ្រោះទុកវិបត្តិជំងឺធ្ងន់ធ្ងរ

## កម្មវត្ថុនៃការធានារ៉ាប់រង

រោគវិនិច្ឆ័យនៃអាការៈជំងឺធ្ងន់ធ្ងររបស់អ្នកត្រូវបានធានារ៉ាប់រង។

## រយៈពេលធានារ៉ាប់រង

រយៈពេលធានារ៉ាបរងរបស់កិច្ចសន្យានេះដូចគ្នាទៅនឹងរយៈពេលធានារ៉ាប់រងរបស់កិច្ចសន្យាធានារ៉ាប់រងមូលដ្ឋាន ហើយត្រូវបានចែងច្បាស់ក្នុងវិញ្ញាបនបត្រធានារ៉ាប់រង។

## លក្ខខណ្ឌនៃការបង់បុព្វលាភ

| | |
|---|---|
| វិធីសាស្ត្របង់បុព្វលាភ | ដូចទៅនឹងផលិតផលមូលដ្ឋាន |
| មធ្យោបាយបង់បុព្វលាភ | ការផ្ទេរប្រាក់តាម App ឬគណនីធនាគារ សាច់ប្រាក់ មូលប្បទានបត្រ |
| ការបំពាន | ដូចទៅនឹងផលិតផលមូលដ្ឋាន |

## អតិបរមានៃសំណងធានារ៉ាប់រង

អតិបរមានៃសំណងធានារ៉ាប់រងសម្រាប់កិច្ចសន្យានេះគឺមានចំនួន ១០០០ ដុល្លារសហរដ្ឋអាមេរិក ឬស្មើនឹងផលគុណនៃ ១០០០ ដុល្លារសហរដ្ឋអាមេរិក។

អតិបរមានៃសំណងធានារ៉ាប់រងអាចត្រូវបានជ្រើសរើសជាប្រភេទថេរ ឬជាប្រភេទប្រែប្រួល។ នៅពេលដាក់ពាក្យស្នើសុំ តម្រូវឲ្យអ្នកស្នើសុំធ្វើការជ្រើសរើសមួយក្នុងចំណោមនោះ។

### ប្រភេទថេរ

ចំពោះប្រភេទថេរគឺសំដៅទៅលើអតិបរមានៃសំណងធានារ៉ាប់រងដែលមិនមានការប្រែប្រួល ចាប់ពីពេលដែលកិច្ចសន្យាធានារ៉ាប់រងនេះចាប់ផ្តើមមានអនុភាពរហូតដល់កិច្ចសន្យាធានារ៉ាប់រងដល់កាលកំណត់។

### ប្រភេទប្រែប្រួល

ចំពោះប្រភេទប្រែប្រួលគឺសំដៅទៅលើអតិបរមានៃសំណងធានារ៉ាប់រងដែលចាប់ផ្តើមពីពេលដែលកិច្ចសន្យានេះគម្រប់ខួប២ឆ្នាំ អតិបរមានៃសំណងធានារ៉ាប់រងដើមគ្រានឹងកើនឡើង ៣% ជារៀងរាល់ឆ្នាំនៃបណ្ណសន្យារ៉ាប់រង។

# វិសាលភាពនៃការធានា

ផលិតផលនេះលើជំងឺធ្ងន់ធ្ងរក្នុងអំឡុងដែលបណ្ណសន្យារ៉ាប់រងកំពុងមានសុពលភាព។

# អត្ថប្រយោជន៍ធានារ៉ាប់រង

ក្នុងអំឡុងពេលដែលកិច្ចសន្យានេះមានអនុភាព ក្រុមហ៊ុននឹងផ្អែកតាមការព្រមព្រៀង ខាងក្រោម ផ្តល់សំណងធានារ៉ាប់រង៖

១ ចាប់ពីថ្ងៃបន្ទាប់នៃថ្ងៃដែលកិច្ចសន្យានេះមានអនុភាពគម្រប់ខួប១ឆ្នាំ រហូតដល់ ថ្ងៃផុតកំណត់នៃរយៈពេលធានារ៉ាប់រង ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងត្រូវបានធ្វើរោគវិនិច្ឆ័យលើកដំបូងរកឃើញជំងឺធ្ងន់ធ្ងរណាមួយដូចដែលមានបញ្ជាក់នៅក្នុងតារាងឧបសម្ព័ន្ធ២៖ "៣៩ ប្រភេទនៃជំងឺធ្ងន់ធ្ងរ" នៃ ខ និងលក្ខខណ្ឌធានារ៉ាប់រង ក្នុងកិច្ចសន្យានេះ ទោះបីជាជំងឺនោះមួយ ឬច្រើនប្រភេទក៏ដោយ ក្រុមហ៊ុនធានារ៉ាប់រងនឹងផ្តល់សំណងធានារ៉ាប់រងសម្រាប់ជំងឺធ្ងន់ធ្ងរជូនអ្នកត្រូវបានធានារ៉ាប់រង ដោយផ្អែកតាមការព្រមព្រៀងដូចខាងក្រោម រួចកិច្ចសន្យាធានារ៉ាប់រងបន្ថែមនេះនឹងត្រូវបញ្ចប់ស្របពេលជាមួយគ្នា។ (ក្នុងករណីកើតហេតុក្នុងអំឡុងពេលដែល កិច្ចសន្យាមានអនុភាពមិនទាន់គ្រប់រយៈពេល ១ឆ្នាំ ក្រុមហ៊ុននឹងប្រគល់ត្រឡប់នូវបុព្វលាភដែលបានបង់ជូនទៅកាន់អ្នកស្នើសុំធានារ៉ាប់រងវិញ)

២ ចំពោះអតិបរមានៃសំណងធានារ៉ាប់រងដែលត្រូវបានជ្រើសរើសជាប្រភេទថេរ ក្រុមហ៊ុននឹងផ្តល់នូវតម្លៃសំណងធានារ៉ាប់រង ដែលស្មើនឹងចំនួនអតិបរមានៃសំណងធានារ៉ាប់រង។

៣ ចំពោះអតិបរមានៃសំណងធានារ៉ាប់រងដែលត្រូវបានជ្រើសរើសជាប្រភេទប្រែប្រួល ក្រុមហ៊ុននឹងផ្តល់នូវតម្លៃសំណងធានារ៉ាប់រង ដែលស្មើនឹងចំនួនអតិបរមានៃសំណងធានារ៉ាប់រងដែលត្រូវបានកើនឡើងឆ្លងកាត់តាមឆ្នាំនៃបណ្ណសន្យារ៉ាប់រង។

### ៣៩ ប្រភេទនៃជំងឺធ្ងន់ធ្ងរ

មហារីកសួត មហារីកថ្លើម មហារីកក្រពះ មហារីកពោះវៀនធំ មហារីកបំពង់អាហារ មហារីកក្រពេញប្រូស្តាត មហារីកតម្រងនោម មហារីកកូនកណ្តុរ មហារីកប្លោកនោម មហារីកគ្រាប់ឈាម មហារីកខួរក្បាល មហារីកលំពែង មហារីកក្រពេញទីរ៉ូអ៊ីត មហារីកអូវែរ មហារីកសុដន់ មហារីកមាត់ស្បូន មហារីកស្បូន ការវះកាត់ផ្លាស់ប្តូរ សរីរាង្គសំខាន់ ឬប្រតិបត្តិការប្តូរកោសិកាឈាម ដំណាក់កាលចុងក្រោយនៃជំងឺ តម្រងនោម ជំងឺរលាកថ្លើមធ្ងន់ធ្ងរ ឬធ្ងន់ធ្ងរនិងស្រួចស្រាវ ដុំសាច់ក្នុងខួរក្បាលប្រភេទស្រាល ដំណាក់កាលធ្ងន់នៃការខូចថ្លើមរ៉ាំរ៉ៃ ផលវិបាកក្រោយជំងឺរលាកខួរក្បាល ឬជំងឺរលាកស្រោមខួរ ការសន្លប់ឈឺង ការបាត់បង់សោតវិញ្ញាណទាំងពីរ ជំងឺគ្មានចលនា វះកាត់សន្ទះបេះដូង ជំងឺខូចខួរក្បាលធ្ងន់ធ្ងរ ការរលាកកម្រិតទី ៣ ធ្ងន់ធ្ងរ សម្ពាធឈាមខ្ពស់ក្នុងសរសៃឈាមដែលផ្តល់ឲ្យសួត ជំងឺកោសិកាប្រសាទ ធ្ងន់ធ្ងរ ការបាត់បង់សមត្ថភាពនិយាយ ជំងឺខ្វះឈាមធ្ងន់ធ្ងរ ការវះកាត់សរសៃឈាមក្រហម ផលវិបាកក្រោយជំងឺពិការបញ្ញា ការងាប់ផ្នែករបស់សាច់ដុំបេះដូង ស្រួចស្រាវ ជំងឺផាកឃីនសាន់ (Parkinson) ធ្ងន់ធ្ងរ ជំងឺអាល់ហ្សៃមឺរ (Alzheimer) ធ្ងន់ធ្ងរ ការវះកាត់ព្យាបាលសរសៃឈាម

# ឧទាហរណ៍



**អ្នកស្រីវ៉ាង**

អាយុ៣២ឆ្នាំ
រៀបការ
គណនេយ្យករជំនាញ

គាត់បានជាវនូវធានារ៉ាប់រង “គម្រោងអនាគតភ្លឺសង្ឃឹមបុត្រធីតា” ជាមួយនឹងការបង់បុព្វលាភរយៈពេល៦ឆ្នាំ សម្រាប់កូនរបស់គាត់ដែលមានអាយុ៤ឆ្នាំ។ គាត់គ្រាន់តែបង់បន្ថែមនូវបុព្វលាភ 0.16 ដុល្លារសហរដ្ឋអាមេរិកជារៀងរាល់ខែដើម្បីជាវនូវ “ធានារ៉ាប់រងបន្ថែមសម្រាប់ជំងឺធ្ងន់ធ្ងរ” នោះកូនរបស់គាត់នឹងទទួលបានការការពារជំងឺធ្ងន់ធ្ងរសរុបចំនួន ៣៩ប្រភេទ។ អ្វីដែលរឹតតែពិសេសនោះ អតិបរមានៃសំណងធានារ៉ាប់រងជំងឺធ្ងន់ធ្ងរនឹងកើនឡើង 3% ជារៀងរាល់ឆ្នាំ មានន័យថានៅពេលដែលកូនគាត់មានអាយុ ២២ឆ្នាំ អតិបរមានៃសំណងធានារ៉ាប់រងនឹងកើនឡើងដល់ចំនួន148%នៃអតិបរមាសំណងធានារ៉ាប់រងដើមគ្រា។

អ្នកស្រីវ៉ាងក៏បានធ្វើការជាវនូវធានារ៉ាប់រង “គម្រោងអនាគតភ្លឺស្វាង” ជាមួយនឹងការបង់បុព្វលាភរយៈពេល១៨ឆ្នាំ សម្រាប់ខ្លួនគាត់ផងដែរ។ គាត់គ្រាន់តែបង់បន្ថែមនូវបុព្វលាភ 0.75 ដុល្លារសហរដ្ឋអាមេរិកជារៀងរាល់ខែដើម្បីជាវនូវ“ធានារ៉ាប់រងបន្ថែម សម្រាប់ជំងឺធ្ងន់ធ្ងរ” នោះគាត់ផ្ទាល់ក៏អាចទទួលបានការការពារជំងឺធ្ងន់ធ្ងរសរុបចំនួន ៣៩ប្រភេទផងដែរ។ អ្វីដែលរឹតតែពិសេសនោះ នៅពេលដែលគាត់មានអាយុ ៥២ឆ្នាំ អតិបរមានៃសំណងធានារ៉ាប់រងនឹងកើនឡើងដល់ចំនួន 157% នៃអតិបរមាសំណងធានារ៉ាប់រងដើមគ្រា។



# ករណីមិនធានា

១.ក្រុមហ៊ុននឹងមិនមានកាតព្វកិច្ចផ្តល់សំណងធានារ៉ាប់រងទៅលើថ្លៃចំណាយព្យាបាលដែលបណ្តាលមកពីជំងឺឬគ្រោះថ្នាក់ជាយថាហេតុដែលមិនស្ថិតក្រោមវិសាលភាពនៃការធានាឡើយ។

២. ប្រសិនបើនៅពេលអ្នកស្នើសុំធានារ៉ាប់រងដាក់ពាក្យស្នើសុំ មិនជូនដំណឹងពិតដល់ក្រុមហ៊ុនមានការលាក់បាំងស្ថានភាពសុខភាពដូចខាងក្រោមរបស់អ្នកត្រូវបានធានារ៉ាប់រង ក្រុមហ៊ុនធានារ៉ាប់រងនឹងមិនមានកាតព្វកិច្ចផ្តល់សំណងធានារ៉ាប់រងឡើយ៖
(១) អ្នកត្រូវបានធានារ៉ាប់រងបានធ្វើរោគវិនិច្ឆ័យថាមានជំងឺធ្ងន់ធ្ងរ ដូចមានបញ្ជាក់ក្នុងតារាងឧបសម្ព័ន្ធ២៖ "៣៩ ប្រភេទនៃជំងឺធ្ងន់ធ្ងរ" នៃ ខ និងលក្ខខណ្ឌធានារ៉ាប់រងក្នុងកិច្ចសន្យាធានារ៉ាប់រងនេះ
(២) អ្នកត្រូវបានធានារ៉ាប់រងបានសង្ស័យថាមានជំងឺធ្ងន់ធ្ងរ ដូចមានបញ្ជាក់ក្នុងតារាងឧបសម្ព័ន្ធ២៖ "៣៩ ប្រភេទនៃជំងឺធ្ងន់ធ្ងរ" នៃខ និងលក្ខខណ្ឌធានារ៉ាប់រងក្នុងកិច្ចសន្យាធានារ៉ាប់រងនេះ និងកំពុងស្ថិតក្នុងដំណាក់កាលនៃការកំណត់រោគវិនិច្ឆ័យ
(៣) អ្នកត្រូវបានធានារ៉ាប់រងបានធ្វើរោគវិនិច្ឆ័យបានរកឃើញថាមានជំងឺរ៉ាំរ៉ៃមួយ ឬច្រើនប្រភេទ ឬជំងឺស្រួចស្រាវ ឬជំងឺសតិអារម្មណ៍
(៤) អ្នកត្រូវបានធានារ៉ាប់រងមានជំងឺ ឬមុខងារភ្នែក ត្រចៀក ឬចលនារាងកាយមានភាពមិនប្រក្រតី
(៥) អ្នកត្រូវបានធានារ៉ាប់រងប្រកបមុខរបរដែលមានហានិភ័យខ្ពស់ដែលក្រុមហ៊ុនមិនអាចធានាបាន។

៣. ក្រុមហ៊ុនធានារ៉ាប់រងមិនមានកាតព្វកិច្ចសងសំណងធានារ៉ាប់រងឡើយ ប្រសិនបើមានព្រឹត្តិការណ៍ស្ថិតក្រោមវិសាលភាពនៃការធានាកើតឡើងដោយសារតែព្រឹត្តិការណ៍ណាមួយដូចខាងក្រោម៖
(១) អ្នកស្នើសុំធានារ៉ាប់រងមានចេតនាធ្វើឃាត ឬបង្ករបួសទៅលើអ្នកត្រូវបានធានារ៉ាប់រង
(២) អ្នកត្រូវបានធានារ៉ាប់រងជាប់ពាក់ព័ន្ធនឹងការវាយតប់គ្នា ការប្រើប្រាស់គ្រឿងស្រវឹង ឬគ្រឿងញៀន និងអ្នកត្រូវបានធានារ៉ាប់រងបង្ករបួសលើខ្លួនឯងដោយចេតនា
(៣)អ្នកត្រូវបានធានារ៉ាប់រងជាប់ពាក់ព័ន្ធនឹងការជ្រមុជទឹក ការលោតឆ័ត្រយោង ការឡើងភ្នំ ការផ្សងព្រេង ការសម្តែងបច្ចេកទេសពិសេស ការប្រណាំងរថយន្ត។
(៤) អ្នកត្រូវបានធានារ៉ាប់រងបើកបរក្នុងស្ថានភាពស្រវឹង បើកបរក្នុងស្ថានភាពគ្រោះថ្នាក់ បើកបរដោយគ្មានបណ្ណបើកបរត្រឹមត្រូវ ឬបើកបរយានយន្តដោយគ្មានការចុះបញ្ជីត្រឹមត្រូវ ដែលបានកំណត់ដោយច្បាប់
(៥) ការពិនិត្យមុន និងក្រោយមានផ្ទៃពោះ ការមានផ្ទៃពោះ (រួមមានកូនក្រៅស្បូន) ការរលូតកូន (រួមទាំងការរំលូតកូន) ការសម្រាលកូន (រួមទាំងការសម្រាលកូនដោយវះកាត់) ការពន្យារកំណើត ការវះកាត់មិនឲ្យមានកូន ការព្យាបាលឲ្យមានកូន និងជំងឺផ្សេងទៀតដែលវិវឌ្ឍន៍ចេញពីជំងឺខាងលើនេះរបស់អ្នកត្រូវបានធានារ៉ាប់រង
(៦) អ្នកត្រូវបានធានារ៉ាប់រងទទួលរងនូវឧប្បត្តិហេតុខាងវេជ្ជសាស្ត្រ ដោយសារការវះកាត់កែសម្ផស្ស ឬការវះកាត់ផ្សេងៗ
(៧) សង្គ្រាម ការប៉ះទង្គិចផ្នែកយោធា ការបះបោរឬការបះបោរប្រដាប់អាវុធ ការផ្ទុះនុយក្លេអ៊ែរ វិទ្យុសកម្មនុយក្លេអ៊ែរឬការចម្លងរោគពីនុយក្លេអ៊ែរ ដែលបណ្តាលឲ្យមានព្រឹត្តិការណ៍ស្ថិតក្រោមវិសាលភាពនៃការធានា។

ចំណាំ៖ ខិត្តប័ណ្ណផ្សព្វផ្សាយនេះគឺជាការពណ៌នាដោយសង្ខេប។ សម្រាប់ព័ត៌មានលម្អិត សូមអាន ខ និងលក្ខខណ្ឌធានារ៉ាប់រង។ ក្នុងករណីដែលកើតមានភាពមិនស៊ីចង្វាក់គ្នា ត្រូវយក ខ និងលក្ខខណ្ឌធានារ៉ាប់រងជាគោល។

## ទំនាក់ទំនងមកកាន់យើងខ្ញុំ


023-989-218 / 098-989-218

service@gc-life.com.kh www.gc-life.com.kh

វែនផាក ផ្ទះលេខ A១២ ផ្លូវR៨ ភូមិ ១ សង្កាត់ស្រះចក ខណ្ឌដូនពេញ
រាជធានីភ្នំពេញ